6-L12-01, Level 12, Tower 2,
Menara PGRM
No. 6 & 8 Jalan Pudu Ulu, Cheras,
56100 Kuala Lumpur, Malaysia

Telephone: +00 (603) 9283 9881
Facsimile: +00 (603) 9284 8187
Email: ia.mysbaenquiry@intertek.com
Website: www.intertek.com

**ICI Ref: R9280/12-4/MRICOP–ASA 03** ៥ មិថុនា ២០១៥

**ភាគីពាក់ព័ន្ធជាទីគោរព!**

គោរពអញ្ជើញចូលរួមធ្វើការអត្ថាធិប្បាយលើការវាយតម្លៃតាមដានប្រចាំឆ្នាំរបស់សមាគម RSPO លើកទី៣ (ASA-03) ដែលមានការពង្រីកវិសាលភាព របស់ក្រុមហ៊ុន ម៉ុង ឬទ្ធី វិនិយោគទុន ដំណាំដូងប្រេង កម្ពុជា (សមាជិកភាពរបស់សមាគម RSPO លេខ ១-០១០៩-១១-000-00) ទៅលើវិញ្ញាបនបត្រពហុរោងចក្រ (Multiple Mill Certification)៖ រោងចក្រចម្រាញ់ប្រេងដូង របស់ក្រុមហ៊ុន MRICOP និង MTSI និងកសិដ្ឋានដូងប្រេង នៅក្នុងខេត្ត ព្រះសីហនុ ប្រទេស កម្ពុជា

ក្រុមហ៊ុន ម៉ុង ឬទ្ធី វិនិយោគទុន ដំណាំដូងប្រេង កម្ពុជា (MRICOP) បានប្រគល់អោយស្ថាប័នវិញ្ញាបនបត្រអន្តរជាតិ (Intertek Certification International Sdn Bhd) ដើម្បីធ្វើការវាយតម្លៃវិញ្ញាបនបត្រពហុរោងចក្ររបស់ខ្លួន ដោយអនុលោមទៅនឹងសេចក្តីត្រូវការនៃគោលការណ៍ និងលក្ខណៈវិនិច្ឆ័យរបស់សមាគម តុមូលស្តីពីប្រេងដូងប្រកបដោយចីរភាព (RSPO P&C) និងស្របតាមសូចនាកររបស់ប្រទេសកម្ពុជា (Cambodian Local Indicators – CLI) និងប្រព័ន្ធវិញ្ញាបនបត្រលើបណ្តាញផ្គត់ផ្គង់របស់សមាគម RSPO (RSPO SCCS) សម្រាប់រោងចក្រចម្រាញ់ប្រេងដូង។

ស្ថាប័ន Intertek Certification International មានផែនការធ្វើការវាយតម្លៃតាមដានប្រចាំឆ្នាំ ជាលើកទីបី (ASA-03) ទៅលើការពង្រីកវិសាលភាពនៃវិញ្ញាបនបត្រពហុរោចក្រនៃក្រុមហ៊ុន MRICOP ពីថ្ងៃទី ៦ ដល់ ១០ ខែ កក្កដា ឆ្នាំ ២០១៥។

ក្នុងការធានាថា ក្រុមហ៊ុនបន្តបំពេញគោលការណ៍ និងលក្ខណៈវិនិច្ឆ័យរបស់RSPO សូចនាកររបស់កម្ពុជា និងប្រព័ន្ធវិញ្ញាបនបត្រ បណ្តាញផ្គត់ផ្គង់របស់ RSPO សម្រាប់រោងចក្រចម្រាញ់ប្រេងដូង និងក្នុងការទទួលបាននូវយោបលត្រឡប់ផ្សេងៗ ស្ថាប័ន Intertek Certification International Sdn Bhd សូមអញ្ជើញភាគីដែលចាប់អារម្មណ៍ ដើម្បីធ្វើអត្ថាធិប្បាយមុននឹងការវាយតម្លៃ របស់ក្រុមហ៊ុន MRICOP ដែលស្ថិតនៅក្នុងខេត្តព្រះសីហនុ។

ក្រុមហ៊ុន ម៉ុង ឬទ្ធី វិនិយោគទុន ដំណាំដូងប្រេង កម្ពុជា បានក្លាយជាសមាជិករបស់សមាគម RSPO តាំងពីថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ ហើយក្រុមហ៊ុនមានការប្តេជ្ញាក្នុងការបំពេញទៅតាមតម្រូវការនៃគោលការណ៍ និងលក្ខណៈវិនិច្ឆ័យរបស់ RSPO និងការបញ្ជាក់ពេញលេញនៅក្នុងគ្រប់ទិដ្ឋភាពនៃការប្រតិបត្តិការរបស់ខ្លួន។ បច្ចុប្បន្ន ក្រុមហ៊ុន ម៉ុង ឬទ្ធី វិនិយោគទុន ដំណាំដូងប្រេង កម្ពុជា ជាម្ចាស់ និងគ្រប់គ្រង រោងចក្រចម្រាញ់ប្រេងដូងចំនួនពីរ និងកសិដ្ឋានចំនួនបី។

សេចក្តីពិស្តារនៃរោងចក្រចម្រាញ់ប្រេងដូងពីរ និងកសិដ្ឋានដូងប្រេង ដែលនឹងត្រូវបានធ្វើការវាយតម្លៃ គឺមានដូចខាងក្រោម៖

អង្គភាពគ្រប់គ្រងចំការ : រោងចក្រចម្រាញ់ប្រេងដូងរបស់ MRICOP, រោងចក្រចម្រាញ់ប្រេងដូងរបស់ MTSI និងកសិដ្ឋានដូងប្រេង។

តារាង ១ : អាសយដ្ឋាន និងទីតាំងនិយាមកា

| ឈ្មោះ | អាសយដ្ឋាន | យោងលេខនិយាមកា | |
|---|---|---|---|
| | | រយៈទទឹង | រយៈបណ្តោយ |
| រោងចក្រចម្រាញ់ប្រេងដូង MRICOP (រោងចក្រ មនោរម្យ) សមត្ថភាព: ៣០ តោន/ម៉ោង | ផ្លូវជាតិលេខ៤, ភូមិមនោរម្យ, ឃុំជើងគោ, ស្រុកព្រៃនប់, ខេត្តព្រះសីហនុ, កម្ពុជា | ១០° ៥៤.៥០' N | ១០៣° ៤៩.៦៥' E |
| រោងចក្រចម្រាញ់ប្រេងដូង MTSI (រោងចក្រ អន្លង់ក្រពើ) សមត្ថភាព: ៤៥ តោន/ម៉ោង | ផ្លូវជាតិលេខ៤, ភូមិអន្លង់ក្រពើ, ឃុំជើងគោ, ស្រុកព្រៃនប់, ខេត្តព្រះសីហនុ, កម្ពុជា | ១០° ៤៩' ០៤.២" N | ១០៣° ៤៨' ៣៣.១" E |
| កសិដ្ឋាន អេ (តាពៅ) | ផ្លូវជាតិលេខ៤, ភូមិតាពៅ, ឃុំជើងគោ, ស្រុកព្រៃនប់, ខេត្តព្រះសីហនុ, កម្ពុជា | ១០° ៤៩' ០៤.២" N | ១០៣° ៤៨' ៣៣.១" E |
| កសិដ្ឋាន ប៊ី (ស្វាយ) | ផ្លូវជាតិលេខ៤, ភូមិស្វាយ, ឃុំជើងគោ, ស្រុកព្រៃនប់, ខេត្តព្រះសីហនុ, កម្ពុជា | ១០° ៥២' ១៥.៥" N | ១០៣° ៥១' ០៥.៣" E |
| កសិដ្ឋាន ស៊ី (អន្លង់ក្រពើ) | ផ្លូវជាតិលេខ៤, ភូមិអន្លង់ក្រពើ, ឃុំជើងគោ, ស្រុកព្រៃនប់, ខេត្តព្រះសីហនុ, កម្ពុជា | ១០° ៥៧' ៣៤.៩" N | ១០៣° ៥៤' ២៨.២" E |

ស្ថាប័ន Intertek Certification International Sdn Bhd [អតីតត្រូវបានគេស្គាល់ថា ជាស្ថាប័ន Moody International Certification (Malaysia) Sdn Bhd] គឺជាផ្នែកមួយនៃគ្រុប Intertek Group ដែលជាអង្គការផ្តល់សេវាកម្មបច្ចេកទេសជាសកលមួយ ដោយផ្តោតទៅលើការកាត់បន្ថយហានិភ័យរបស់អតិថិជន ដោយផ្តល់សេវាកម្មត្រួតពិនិត្យបច្ចេកទេស, វិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រង ទៅលើគុណភាព បរិស្ថាន សុវត្ថិភាព និងសុខភាពនៅកន្លែងការងារ និងការបញ្ជាក់ពីផលិតផល, វិញ្ញាបនបត្របណ្តាញផ្គត់ផ្គង់របស់សមាគម RSPO (RSPO SCC), វិញ្ញាបនបត្របណ្តាញផ្គត់ផ្គង់អន្តរជាតិ (ISCC), ខាងបណ្តាញគាំពារផ្នែកជើងទឹកប្រកបដោយចីរភាព, MTCS និងវិញ្ញាបនបត្របណ្តាញគាំពារ PEFC នៅក្នុងវិស័យឧស្សាហកម្មដែលអាចអនុវត្តបាន រួមទាំងវិស័យកសិកម្ម និងព្រៃឈើ។ ស្ថាប័ន Intertek ប្រតិបត្តិទូទាំងសកលលោកក្នុងការផ្តល់នូវភាពជំនាញខាងអធិការកិច្ចបច្ចេកទេសយ៉ាងទូលំទូលាយ និងអាចទទួលបាននូវអ្នកឯកទេសដ៏មានជំនាញ នៅក្នុងសកលលោក។ ជំនួញវិញ្ញាបនបត្ររបស់គ្រុប Intertek Group គឺត្រូវបានជាប់ចំណាត់ថ្នាក់ ក្នុងលំដាប់កំពូលទាំង ១០ នៅទូទាំងពិភពលោក និងមានលទ្ធភាពជាសកលក្នុងការផ្តល់វិញ្ញាបនបត្រក្នុងវិស័យឧស្សាហកម្មដ៏ទូលំទូលាយ។

ស្ថាប័ន Intertek Certification International Sdn Bhd បានចាត់តាំងក្រុមសម្រាប់ការវាយតម្លៃដូចខាងក្រោម៖

- ប្រធានក្រុមអ្នកវាយតម្លៃ
  - លោក Augustine Loh (ខាងរោងចក្រចម្រាញ់ប្រេងដូង, បណ្តាញផ្គត់ផ្គង់, បរិស្ថាន, សុវត្ថិភាព និងសុខភាពនៅកន្លែងការងារ, ការប្រើប្រាស់ដីធ្លី)
- អ្នកវាយតម្លៃ
  - លោក Chen Fai Kok (ខាងការអនុវត្តន៍ល្អខាងកសិកម្ម និងវិធានការចម្រុះថៃទាំងដំណាំ)
  - លោក Sazali Hasni (ខាងបរិស្ថាន និងតំបន់ដែលមានតម្លៃខ្ពស់សម្រាប់អភិរក្ស)
  - អ្នកស្រី Ham Fin Lan (ខាងសង្គម)
  - លោក Reaksa Rous (អ្នកជំនាញក្នុងស្រុក - ច្បាប់ និងប្បញ្ញត្តិក្នុងស្រុក)

ដោយផ្អែកទៅលើការវាយតម្លៃ ដែលនឹងធ្វើឡើងនៅទីតាំងដូចដែលបានរៀបរាប់ខាងលើ ស្ថាប័ន Intertek Certification International Sdn Bhd សូមស្វាគមន៍ភាគីពាក់ព័ន្ធ ដើម្បីផ្តល់នូវមតិយោបល់ទៅលើបញ្ហានានាខាងក្រោម ដែលទាក់ទងទៅនឹងទីតាំងដែលនឹងត្រូវធ្វើការវាយតម្លៃ៖

- ការការពារបរិស្ថាន
- ឳកាសការងារ
- បញ្ហាដ៏ទៃទៀតដែលទាក់ទងសម្រាប់ការវាយតម្លៃ
- ការអភិរក្សជីវៈចម្រុះ
- ការអភិវឌ្ឍន៍សហគមន៍

រាល់មតិយោបល់ដែលនឹងត្រូវទទួលក្នុងកំឡុងពេល ៣០ ថ្ងៃ ចាប់តាំងពីការបរិច្ឆេតនៃលិខិតនេះ នឹងយកទៅពិចារណានៅក្នុងការវាយតម្លៃវិញ្ញាបនបត្រ។ សូមផ្តល់មតិយោបល់ដោយផ្ទាល់ទៅ


លោក Augustine Loh
ប្រធានកម្មវិធី RSPO
Intertek Certification International Sdn Bhd
6-L12-01, Level 12, Tower 2, Menara PGRM,
No. 6 & 8, Jalan Pudu Ulu Cheras,
56100 Kuala Lumpur, Malaysia
Tel: 603 9283 9881 Fax: 603 9284 8187
Email: Augustine.loh@intertek.com

លោក Sumate Pratumsuwan
អគ្គនាយករង ទទួលបន្ទុកកសិកម្មដូងប្រេង
Mong Reththy Investment Camodia Oil Palm Co.Ltd
ភូមិមនោរម្យ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ
Tel: (855-85) 903 551
Fax: (855-23) 216 496
Email: summate.p@tccagroindustrial.com


យើងសូមអរគុណសម្រាប់មតិយោបល់ និងយោបល់ត្រឡប់របស់អស់លោកអ្នក
ដោយសេចក្តីគោរព


Augustine Loh
RSPO Program Manager
Intertek Certification International Sdn Bhd